# ក្រុមបឹក្សាសិទ្ធិមនុស្ស

## សេចក្តីសំរេចចិត្តលេខ៩/១៥ សេវាប្រឹក្សាយោបល់និងការជួយឧបត្ថម្ភផ្នែកបច្ចេកទេសសំរាប់កម្ពុជា

*ក្រុមប្រឹក្សាសិទ្ធិមនុស្ស*

*ដោយអះអាងជាថ្មីថា* រដ្ឋជាសមាជិកទាំងអស់មានកាតព្វកិច្ចលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចបានតំកល់ក្នុងធម្មនុញ្ញសហប្រជាជាតិ ដូចបានអះអាងជាថ្មីក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងស្របតាមកាតព្វកិច្ចរបស់ខ្លួនរៀងៗខ្លួន ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សឯទៀត ដែលកំពុងស្ថិតនៅជាធរមាន។

*ដោយរំលឹកឡើងវិញ* អំពីសេចក្តីសំរេចចិត្តរបស់មហាសន្និបាត លេខ ៦០/២៥១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦។

*ដោយរំលឹកឡើងវិញផងដែរ* អំពីសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សា លេខ ៥/១ ស្តីពីការបង្កើតស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងសេចក្តីសំរេចចិត្ត លេខ ៥/២ ស្តីពីក្រមសីលធមិសំរាប់អ្នកកាន់អាណត្តិនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ និងគូសបញ្ជាក់ថាអ្នកកាន់អាណត្តិត្រូវអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ស្របតាមសេចក្តីសំរេចចិត្ត និងឧបសម្ព័ន្ធនៃសេចក្តីសំរេចចិត្តទាំងនោះ។

*ដោយចងចាំក្នុងចិត្ត* អំពីសេចក្តីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ ២០០៥/៧៧ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥។

*ដោយចងចាំក្នុងចិត្តផងដែរ* អំពីរបាយការណ៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា（A/HRC/7/42）និងអនុសាសន៍ក្នុងរបាយការណ៍នោះ និងរបាយការណ៍របស់អគ្គលេខាធិការអ.ស.ប ស្តីពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងការជួយដល់រដ្ឋាភិបាលនិងប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស（A/HRC/7/56）។

*ដោយទទួលស្គាល់* អំពីប្រវត្តិសាស្ត្រដ៏មហាសោកនាដកម្មនាពេលថ្មីៗនេះរបស់កម្ពុជា ដែលទាមទារការចាត់វិធានការពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស និងការមិនវិលត្រឡប់មកវិញនូវនយោបាយ និង

ទម្លាប់អនុវត្តក្នុងអតីតកាល ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយមួយនូវជំលោះនៃប្រទេសកម្ពុជា ដែលបានចុះហត្ថលេខានាទីក្រុងប៉ារីសកាលពីថ្ងៃទី២៣ ខែតុលាឆ្នាំ១៩៩១។

*ដោយកត់សំគាល់* អំពីការវិវត្តន៍ថ្មីៗនៅកម្ពុជា ជាពិសេស ការវិវត្តន៍ទាំងឡាយដែលទាក់នឹងភាពជឿនលឿន និងកិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ របស់រដ្ឋាភិបាលកម្ពុជា ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ជាពិសេស ក្នុងសមិទ្ធិផលនិងការរីកចំរើននៃវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និងវប្បធម៌នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ តាមរយៈផែនការ យុទ្ធសាស្ត្រ និងក្របខ័ណ្ឌជាតិពាក់ព័ន្ធរបស់ខ្លួន។

## I- <u>សាលាក្ដីខ្មែរក្រហម</u> :

១- *ដោយអះអាងជាថ្មី* អំពីសារៈសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានគោលដៅកាត់សេចក្ដីករណីរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត ដែលបានប្រព្រឹត្តនៅក្នុងរបបគ្រប់គ្រងរបស់ខ្មែរក្រហម ហើយជឿជាក់ថា វានឹងជួយជាវិភាគដ៏សំខាន់ដល់ការបំបាត់បញ្ហានិទណ្ឌភាព និងការបង្កើតនីតិរដ្ឋតាមរយៈការងាររបស់តុលាការគំរូនេះ នៅកម្ពុជា។

២- *សូមស្វាគមន៍* ចំពោះការជឿនលឿនទៅមុខនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរួមទាំងការឃុំខ្លួនជនសង្ស័យសំខាន់ៗប្រាំរូប ក្នុងឆ្នាំ២០០៧ និងការដាក់បញ្ជូនដីកាបិទលើកទីមួយ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ និងការគាំទ្រជំហររបស់រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីបន្តកាត់សេចក្ដីក្នុងលក្ខណៈត្រឹមត្រូវ ឆាប់រហ័ស និងមានប្រសិទ្ធភាព ដោយសារថា ជនជាប់ចោទមានវ័យចំនាស់ខ្លាំងនិងមានសុខភាពមិនមាំមួន និងយុត្តិធម៌ដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំជាយូរមកហើយនោះ ។

៣- *សូមស្វាគមន៍ផងដែរ* ចំពោះការជួយឧបត្ថម្ភរបស់រដ្ឋមួយចំនួនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយកត់សំគាល់អំពីការស្ទង់មើលថវិកាពិនិត្យឡើងវិញដែលបានអនុម័តយល់ព្រមកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ លើកទឹកចិត្តដល់រដ្ឋាភិបាលកម្ពុជា អោយធ្វើការជាមួយអង្គការសហប្រជាជាតិ និងរដ្ឋទាំងឡាយដែលផ្ដល់ការជួយឧបត្ថម្ភ ដើម្បីធានាការគ្រប់គ្រងក្នុងក៏រិតស្តង់ដាខ្ពស់បំផុតនៃអង្គជំនុំជម្រះវិសាមញ្ញ និងអំពាវនាវសុំការជួយឧបត្ថម្ភថែមទៀតដល់អង្គជំនុំជម្រះវិសាមញ្ញអោយបានឆាប់រហ័ស ដើម្បីធានាអោយសាលាក្ដីនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

## II- <u>លទ្ធិប្រជាធិបតេយ្យ និង ស្ថានការណ៍សិទ្ធិមនុស្ស</u>

*៤- សូមស្វាគមន៍ :*

(ក) កិច្ចខិតខំប្រឹងប្រែង និងការរីកចំរើនរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការលើកកំពស់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រួមទាំងការអនុម័ត និងឬ ពង្រឹងការអនុវត្តន៍ច្បាប់គោលមួយចំនួនដូចជា ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី។

(ខ) កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមមានការព្រាងច្បាប់ប្រឆាំងអំពើពុករលួយ និងការខិតខំប្រឹងប្រែងនាំខ្លួនមន្ត្រីពុករលួយទៅតុលាការដើម្បីកាត់ទោសទៅតាមច្បាប់។

(គ) កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស រួមមានការបង្កើតក្រុមការងារពិសេសថ្នាក់ជាតិមួយប្រឆាំងការជួញដូរមនុស្ស ក្នុងខែមេសា ឆ្នាំ២០០៧ បង្កើនវិធានការពង្រឹងអនុវត្តច្បាប់ប្រឆាំងអ្នកជួញដូរមនុស្ស និងមន្ត្រីសមគំនិត និងការប្រកាសឱ្យប្រើច្បាប់ថ្មីស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ក្នុងខែកុម្ភៈ ឆ្នាំ២០០៨។

(ឃ) កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាដីធ្លី តាមរយៈការអនុវត្តន៍កម្មវិធីកំណែទម្រង់ដីធ្លី ជាពិសេស តាមរយៈការពង្រីកវិសាលភាពប្រកបដោយជោគជ័យនៃកម្មវិធីកំណត់ព្រំដី និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ។

(ង) ការសន្យារបស់រដ្ឋាភិបាលកម្ពុជា ក្នុងការប្រកាន់ខ្ជាប់ និងការអនុវត្តន៍អនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា រួមមាន ការសន្យារបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងឱកាសបើកកិច្ចប្រជុំក្រៅផ្លូវការលើកទីប្រាំបីអាស៊ី-អឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលបានធ្វើនៅខេត្តសៀមរាប ក្នុងខែកញ្ញា ឆ្នាំ២០០៧ ដែលរួមទាំង ការលើកឡើងអំពីការគ្រោងបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ។

(ច) កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាពិសេស ក្នុងការដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋ ការធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពពន្ធនាគារ និងការធ្វើអន្តរាគមន៍ចំពោះការឃុំខ្លួនលើសនីតិវិធី ។

(ឆ) ការប្រកាន់ខ្ជាប់របស់រដ្ឋាភិបាលកម្ពុជា ចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា រួមមាន ការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម ក្នុងខែមីនា ឆ្នាំ២០០៧ ការសុំចូលជាសមាជិក

នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ក្នុងខែកញ្ញា ឆ្នាំ២០០៧ និងការចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ក្នុងខែតុលា ឆ្នាំ២០០៧ ។

(ជ) ការបន្តជាថ្មីនូវអនុស្សារណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សំរាប់ការអនុវត្តន៍កម្មវិធីនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសលើវិស័យសិទ្ធិមនុស្ស ក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ និងលើកទឹកចិត្តដល់ភាគីទាំងពីរឱ្យសហការគ្នាក្នុងន័យស្ថាបនា ដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀត ដល់ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ។

(ឈ) ការគ្រប់គ្រងល្អ និងការបញ្ចប់ទៅដោយសន្តិភាពជាទូទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងខែកក្កដា ឆ្នាំ២០០៨ បានបង្ហាញឱ្យឃើញពីការបន្តអភិវឌ្ឍន៍ដំណើរការលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ទន្ទឹមនឹងនេះក៏កត់សំគាល់ឃើញមានចំណុចខ្វះខាតខ្លះ អំពីការរៀបចំដំណើរការការបោះឆ្នោត និងទទួលស្គាល់អំពីសេចក្តីត្រូវការការពង្រឹងសមត្ថភាពការងារបន្ថែមទៀត ដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

(ញ) កិច្ចខិតខំប្រឹងប្រែង និងការរីកចំរើនដែលរដ្ឋាភិបាលកម្ពុជាសំរេចបានក្នុងការលើកកំពស់កំណែទម្រង់ប្រព័ន្ធវិមជ្ឈការ និងសហវិមជ្ឈការ ក្នុងគោលដៅធ្វើឱ្យសំរេចនូវការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យតាមរយៈការពង្រឹងស្ថាប័ននានាក្រោមថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន រួមទាំងការបោះឆ្នោតនៅថ្នាក់មូលដ្ឋានខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ដែលបានគ្រោងធ្វើនៅឆ្នាំ២០០៩។

*៥- សំដែងនូវកង្វល់របស់ខ្លួន* អំពីវិស័យមួយចំនួននៃការអនុវត្តន៍ផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ហើយស្នើយ៉ាងទទូចដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យ :

(ក) បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការបង្កើតនីតិរដ្ឋ ដោយរួមទាំង តាមយៈការអនុម័ត និងការអនុវត្តន៍ច្បាប់ និងក្រមសំខាន់ៗសំរាប់បង្កើតសង្គមប្រជាធិបតេយ្យមួយ និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធមិ ជាពិសេស ដើម្បីធានាឯករាជ្យភាព ភាពមិនលំអៀង តម្លាភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធមិទាំងមូល ។

(ខ) បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ជាពិសេស តាមរយៈការអនុម័តឱ្យបានឆាប់រហ័សនូវច្បាប់ប្រឆាំងអំពើពុករលួយ និងការអនុវត្តន៍ច្បាប់នេះ ។

(គ) បន្តដោះស្រាយ ជាបញ្ហាអាទិភាព ក្នុងចំណោមបញ្ហាឯទៀត នូវបញ្ហានិទណ្ឌភាព និងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេតជាបន្ទាន់ និងកាត់ទោសទៅតាមនីតិវិធីត្រឹមត្រូវរបស់

ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ចំពោះជនទាំងឡាយដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ រួមទាំងការរំលោភសិទ្ធិមនុស្សផងដែរ ។

(ឃ) បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាកម្មសិទ្ធិដីធ្លីដោយសមធម៌ និងឆាប់រហ័ស ដោយចំហរ និងត្រឹមត្រូវ ស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ តាមរយៈការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័នពាក់ព័ន្ធនានា ដូចជាអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការសុរិយោដីថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ។

(ង) បន្តបង្កលក្ខណៈងាយស្រួល សំរាប់ការធ្វើសកម្មភាពនយោបាយស្របច្បាប់ និងគាំទ្រដល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអភិវឌ្ឍន៍លិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

(ច) បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកស្ទួយសិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រី និងកុមារ និងខិតខំប្រឹងប្រែងថែមទៀត ដោយសហការជាមួយសហគមអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាធំៗមួយចំនួន ដូចជាការជួញដូរមនុស្ស បញ្ហាទាក់ទងនឹងភាពក្រីក្រ អំពើហឹង្សាផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

(ឆ) ចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការថែមទៀត ជាមួយទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ រួមមាន ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ព្រមទាំងតាមរយៈការពង្រឹងការពិភាក្សា និងការបង្កើតឱ្យមានសកម្មភាពការងាររួមគ្នា ។

(ជ) បន្តលើកស្ទួយសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការផ្តល់សេរីភាពខាងនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច តាមរយៈការបន្ត និងពង្រឹងការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ និងកម្មវិធីកំណែទម្រង់ផ្សេងៗទៀត របស់ខ្លួន ។

## III- <u>សេចក្តីសន្និដ្ឋាន</u>

៦- *សូមអញ្ជើញ* អគ្គលេខាធិការ ទីភ្នាក់ងារនានាក្នុងប្រព័ន្ធសហប្រជាជាតិដែលមានវត្តមាននៅកម្ពុជា និងសហគមន៍អន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលនានា បន្តធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងលិទ្ធិប្រជាធិបតេយ្យ ក៏ដូចជា ធានាការការពារ និងការលើកស្ទួយសិទ្ធិមនុស្សរបស់ប្រជាជនគ្រប់រូបនៅកម្ពុជា រួមទាំងតាមរយៈការជួយឧបត្ថម្ភ ដែលក្នុងនោះមាន :

(ក) ការរៀបចំព្រាងច្បាប់ចាំបាច់ផ្សេងៗដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្ស

(ខ) ការកសាងសមត្ថភាពដើម្បីពង្រឹងស្ថាប័នច្បាប់ រួមទាំង តាមរយៈការពង្រឹងគុណភាពចៅក្រម ព្រះរាជអាជ្ញា មេធាវី និងបុគ្គលិកតុលាការ

(គ) ការកសាងសមត្ថភាពដើម្បីពង្រឹងស្ថាប័នជាតិ សំរាប់ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ និងការពង្រឹងអនុវត្តច្បាប់ ក៏ដូចជា ការផ្តល់ឧបករណ៍ចាំបាច់ ដើម្បីធ្វើអោយសំរេចគោលដៅទាំងនេះ

(ឃ) ជួយធ្វើការវាស់ស្ទង់អំពីភាពរីកចំរើនក្នុងវិស័យសិទ្ធិមនុស្ស

៧- *ជំរុញលើកទឹកចិត្ត* ដល់រដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ ឱ្យផ្តល់ការជួយឧបត្ថម្ភចាំបាច់គ្រប់បែបយ៉ាងដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីករណីរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតក្នុងប្រទេសនេះ ដើម្បីធានាការមិនវិលត្រឡប់មកវិញនូវនយោបាយ និងទម្លាប់អនុវត្តក្នុងអតីតកាល ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយមួយ នូវជំលោះនៃប្រទេសកម្ពុជា។

៨- *ដោយកត់សំគាល់* អំពីការងារដែលតំណាងពិសេសរបស់លោកអគ្គលេខាធិការបានធ្វើ ទាក់ទងនឹងស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា និងអំពីការសន្យាជាថ្មីរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សជាមួយរដ្ឋាភិបាលកម្ពុជា។

៩- *សំរេច* បន្តម្តងមួយឆ្នាំនូវអាណត្តិរបស់នីតិវិធីពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា តាមរយៈការតែងតាំងអ្នករាយការណ៍ពិសេសមួយរូប អោយបំពេញមុខងារកន្លងមករបស់តំណាងពិសេសរបស់លោកអគ្គលេខាធិការ និងស្នើអោយអ្នករាយការណ៍ពិសេស រាយការណ៍អំពីការអនុវត្តន៍អាណត្តិរបស់ខ្លួន ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនាសម័យប្រជុំលើកទីដប់ពីររបស់ខ្លួន និងចូលរួមក្នុងន័យស្ថាបនាជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀត ដល់ស្ថានការណ៍សិទ្ធិមនុស្សក្នុងប្រទេសនេះ។

១០- *ស្នើអោយ* អគ្គលេខាធិការ រាយការណ៍ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនាសម័យប្រជុំលើកទីដប់ពីររបស់ខ្លួន អំពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាលនិងប្រជាជនរដ្ឋកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស។

១១- *បានសំរេច* បន្តការពិនិត្យពិចារណារបស់ខ្លួន អំពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជានាសម័យប្រជុំលើកទីដប់ពីរ របស់ខ្លួន ។